ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៩៤ សជណ.ធទឧ

# សេចក្ដីជូនដំណឹងបន្ថែម

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងបន្ថែមដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការសង្កេត និងតាមដានលើស្ថានភាពអាកាសធាតុរួចមក ឃើញថា : ព្យុះទី 8 ឈ្មោះ **ណុកថិន** ( NOCK-TEN ) ដែលបានកើតនៅមហាសមុទ្រប៉ាស៊ីហ្វិក កាលពីម៉ោង 01 h 00 រំលងអធាត្រ ឈានចូលថ្ងៃទី 27 ខែកក្កដា ឆ្នាំ 2011 នោះ បានធ្វើដំណើរឆ្លងកាត់ប្រទេសហ្វីលីពីន ឆ្ពោះទៅទិសពាយ័ព្យ ។ បច្ចុប្បន្ន ព្យុះនេះកំពុងស្ថិតនៅក្នុងសមុទ្រចិនខាងត្បូង ត្រង់ចំណុចខ្សែស្របទី 116 អង្សា 3 នៃរយៈបណ្ដោយខាងកើត និងខ្សែរីយ៉ូទី 18 អង្សា 1 នៃរយៈទទឹងខាងជើង ។ ព្យុះ **ណុកថិន** នឹងធ្វើដំណើរឆ្លងកាត់កោះហៃណាំ ឆ្ពោះទៅប្រទេសវៀតណាម និងប្រទេសឡាវភាគខាងជើង ក្នុងល្បឿន 27 km/h ។ ព្យុះនេះនឹងមានឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជា និងអាងទន្លេមេគង្គ ចាប់ពីថ្ងៃទី 30 ខែកក្កដា រហូតដល់ថ្ងៃទី 02 ខែសីហា ឆ្នាំ 2011 ។ ស្ថានភាពបែបនេះនឹងបង្កឱ្យ :

- **តំបន់ខ្ពង់រាបភាគខាងជើង និងខ្ពង់រាបភាគឦសាន :** មានភ្លៀងធ្លាក់ច្រើន មានល្បឿនខ្យល់ខ្លាំង និងអាចបង្កឱ្យមានជំនន់ទឹកភ្លៀងនៅតាមបណ្ដាខេត្តមួយចំនួនដូចជា : ខេត្តឧត្តរមានជ័យ ព្រះវិហារ ស្ទឹង-ត្រែង ក្រចេះ រតនគិរី និងខេត្តមណ្ឌលគិរី ។
- **តំបន់វាលទំនាបកណ្ដាល :** មានភ្លៀងធ្លាក់ច្រើន មានល្បឿនខ្យល់ខ្លាំង និងអាចបង្កឱ្យមានជំនន់ទឹកភ្លៀងនៅតាមបណ្ដាខេត្តមួយចំនួនដូចជា : ខេត្តបន្ទាយមានជ័យ សៀមរាប កំពង់ចាម និងខេត្តកំពង់ធំ ។
- **តំបន់មាត់សមុទ្រ :** មានភ្លៀងធ្លាក់ច្រើន មានល្បឿនខ្យល់ខ្លាំង និងអាចបង្កឱ្យមានជំនន់ទឹកភ្លៀង នៅតាមបណ្ដាខេត្តមួយចំនួនដូចជា : ខេត្តកោះកុង ព្រះសីហនុ កំពត និងខេត្តកែប ព្រមទាំងកំណាត់ផ្លូវជាតិលេខ 4 ផងដែរ ។ រលកសមុទ្រមានកំពស់ពី 1,00 m ទៅ 2,50 m ។

ឥទ្ធិពលនៃព្យុះនេះក៏នឹងធ្វើឱ្យកំពស់ទឹកទន្លេមេគង្គបន្តហក់ឡើងបន្ថែមទៀត ។

យោងតាមសភាពការណ៍ធាតុអាកាសខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេមេគង្គ និងតាមបណ្ដាខេត្តដូចបានជម្រាបជូនខាងលើ ពិសេសបងប្អូនប្រជានេសាទ សូមបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នបន្ថែមទៀត ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតឡើងជាយថាហេតុ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១១*

**រដ្ឋមន្ត្រី**

**លឹម_គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh